ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា
លេខ :...១២៥២.......ន.ទ.ក.

## សេចក្តីណែនាំ
## ស្តីពី
## ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញយកក្រុមហ៊ុនឬភាគហ៊ុន ឬការដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងការធ្វើបច្ចុប្បន្នភាពសម្រង់ព័ត៌មាននៃថ្នាក់គ្រប់គ្រងរបស់ប្រតិបត្តិករទូរគមនាគមន៍

អនុលោមតាមមាត្រា ២២ និង មាត្រា ៦៣ នៃច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតដែលនៅជាធរមាន និយ័តករទូរគមនាគមន៍កម្ពុជា (**ន.ទ.ក.**) មានកិត្តិយសសូមជម្រាបជូនប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទាំងអស់ឱ្យបានជ្រាបថា ៖

**ទី១.** ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញយកក្រុមហ៊ុនឬភាគហ៊ុន ឬការដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ទ.ក.**។ ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញយកក្រុមហ៊ុនឬភាគហ៊ុន ឬការដាក់ប្រាតិភោគ ពុំមានសុពលភាពនោះទេក្នុងករណីដែលពុំមានការយល់ព្រមជាមុនពី **ន.ទ.ក.**។

**ទី២.** ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញយកក្រុមហ៊ុនឬភាគហ៊ុន ឬការដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវគោរពតាមនីតិវិធីដូចគ្នាទៅនឹងការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ស្របតាមច្បាប់ស្តីពីទូរគមនាគមន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត និងត្រូវបង់កម្រៃសេវាស្របតាមបទប្បញ្ញត្តិជាធរមាន។

ទន្ទឹមនឹងនេះ ដើម្បីធានាប្រសិទ្ធភាពក្នុងការត្រួតពិនិត្យ និងតាមដានការធ្វើប្រតិបត្តិការទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា **ន.ទ.ក.** តម្រូវឱ្យប្រតិបត្តិករទូរគមនាគមន៍ទាំងអស់អនុវត្តដូចខាងក្រោម៖

**ទី១.** ករណីមានការផ្លាស់ប្តូរនាមករណ៍ ឬអាសយដ្ឋានក្រុមហ៊ុន ប្រតិបត្តិករទូរគមនាគមន៍ត្រូវស្នើសុំមក **ន.ទ.ក.** ដើម្បីធ្វើបច្ចុប្បន្នភាពនាមករណ៍ ឬអាសយដ្ឋានក្រុមហ៊ុននៅក្នុងអាជ្ញាបណ្ណ ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារអនុញ្ញាតឱ្យផ្លាស់ប្តូរនាមករណ៍ ឬអាសយដ្ឋានក្រុមហ៊ុន ដែលចេញដោយក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងត្រូវបង់កម្រៃសេវាស្របតាមបទប្បញ្ញត្តិជាធរមាន។

**ទី២.** ជូនដំណឹងមក **ន.ទ.ក.** ជាបន្ទាន់ ករណីមានការផ្លាស់ប្តូរលក្ខន្តិកៈក្រុមហ៊ុន ឬ ប្រធានឬសមាជិកក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ នាយកផ្នែកហិរញ្ញវត្ថុ នាយកផ្នែកបច្ចេកទេស ឬជនបង្គោលសម្រាប់ទំនាក់ទំនងព័ត៌មានរបស់ក្រុមហ៊ុន ។

**ទី៣.** ផ្តល់សម្រង់ព័ត៌មានអំពី ម្ចាស់ភាគហ៊ុន ប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ នាយកផ្នែកហិរញ្ញវត្ថុ នាយកផ្នែកបច្ចេកទេស និងជនបង្គោលសម្រាប់ទំនាក់ទំនងព័ត៌មាន ជូនមក **ន.ទ.ក.** ឱ្យបានមុនដំណាច់ខែធ្នូ ជារៀងរាល់ឆ្នាំ ដោយភ្ជាប់ជាមួយនូវលក្ខន្តិកៈក្រុមហ៊ុនចុងក្រោយ។ ចំពោះសម្រង់ព័ត៌មានសម្រាប់ឆ្នាំ២០២០ ប្រតិបត្តិករទូរគមនាគមន៍ត្រូវផ្តល់មក **ន.ទ.ក.** ក្នុងរយៈពេល ៧ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយកាលបរិច្ឆេទនៃសេចក្តីណែនាំនេះ។

អាស្រ័យដូចបានណែនាំខាងលើ សូម ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ មេត្តាជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាពបំផុត។

ថ្ងៃអង្គារ ១០ កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២០

**ប្រធាន**

ម៉ូច ចរិយា

**ចម្លងជូន៖**

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ «ដើម្បីជូនជ្រាប»
- ឯកសារ-កាលប្បវត្តិ

# <u>សម្រង់ព័ត៌មានទំនាក់ទំនង (Focal Persons)</u>

**១) ព័ត៌មានទូទៅ** (General Information)

ឈ្មោះក្រុមហ៊ុន (Company Name):______________________________

អាសយដ្ឋាន (Address):______________________________

______________________ លេខទូរស័ព្ទ (Tel):______________________

**២) ព័ត៌មានម្ចាស់ភាគហ៊ុន** (Shareholder Information)

ឈ្មោះបុគ្គល/ក្រុមហ៊ុន (Individual/Company Name):______________________

សញ្ជាតិ (Nationality):____________ អត្តសញ្ញាណប័ណ្ណលេខ (ID Card/Passport No.):____________

អាសយដ្ឋាន (Address):______________________________

______________________________

- ❖ ប្រធានក្រុមប្រឹក្សាភិបាល (Board of Director Information)

ឈ្មោះ (Name):______________________ សញ្ជាតិ (Nationality):______________

- ❖ អភិបាល (Director Information)

ឈ្មោះ (Name):______________________ សញ្ជាតិ (Nationality):______________

**៣) ព័ត៌មានទំនាក់ទំនងថ្នាក់គ្រប់គ្រង**

- ❖ នាយកប្រតិបត្តិ (CEO Information)

ឈ្មោះ (Name):______________________ សញ្ជាតិ (Nationality):______________

អាសយដ្ឋានអ៊ីម៉ែល (Email): ______________________ លេខទូរស័ព្ទ (Tel): ______________

- ❖ នាយកផ្នែកហិរញ្ញវត្ថុ (CFO Information)

ឈ្មោះ (Name):______________________ សញ្ជាតិ (Nationality):______________

អាសយដ្ឋានអ៊ីម៉ែល (Email): ______________________ លេខទូរស័ព្ទ (Tel): ______________

- ❖ នាយកផ្នែកបច្ចេកទេស (CTO Information)

ឈ្មោះ (Name):______________________ សញ្ជាតិ (Nationality):______________

អាសយដ្ឋានអ៊ីម៉ែល (Email): ______________________ លេខទូរស័ព្ទ (Tel): ______________

- ❖ ជនបង្គោល ( Focal Person information)

ឈ្មោះ (Name):______________________ សញ្ជាតិ (Nationality):______________

អាសយដ្ឋានអ៊ីម៉ែល (Email): ______________________ លេខទូរស័ព្ទ (Tel): ______________

**សម្គាល់៖** - សូមភ្ជាប់លក្ខន្តិកៈចុងក្រោយជាមួយទម្រង់សម្រង់ព័ត៌មានទំនាក់ទំនងខាងលើ

- ទម្រង់សម្រង់ព័ត៌មានអេឡិចត្រូនិកអាចទាញយកបានតាមរយៈ:

<u>https://www.trc.gov.kh/wp-content/uploads/2020/06/Focal-Persons.docx</u>

ស.ស.